# សាធារណរដ្ឋប្រជាមានិត កុងហ្គោ

## សេចក្តីសង្ខេបលើកម្មវិធីជួយអ្នកមានជីវិតរស់ពីគ្រាប់មីន

| ចំនួនសរុបនៃអ្នករងគ្រោះថ្នាក់ដោយសារមីន/សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ចាប់ពីឆ្នាំ១៩៩៦: យ៉ាងហោចណាស់មានអ្នកនៅរស់ មានជីវិតចំនួន ២១៨៤ នាក់ | | | |
|---|---|---|---|
| ឆ្នាំ | សរុប | ស្លាប់ | របួស |
| ២០០៤ | ៦១ | ១៦ | ៤៥ |
| ២០០៥ | ៦០ | ១៨ | ៤២ |
| ២០០៦ | ៤៤ | ១៧ | ២៧ |
| ២០០៧ | ២៨ | ៤ | ២៤ |
| ២០០៨ | ១៤ | ៣ | ១១ |
| **សរុប** | **២០៧** | **៥៨** | **១៤៩** |

- **ចំនួនប៉ាន់ស្មាននៃអ្នករស់រានពីគ្រាប់មីន /សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម:** មិនដឹង។ ប៉ុន្តែយ៉ាងតិចមានចំនួន ១២៤៧ នាក់។
- **ស្ថាប័នសម្របសម្រួល/ក្រុមបង្គោលជំនួយជនរងគ្រោះ:** នាយកកម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍នៃក្រសួងសុខាភិបាល គឺជាជនបង្គោលនៃជំនួយជនរងគ្រោះ ប៉ុន្តែមនុស្សនេះខ្វះមធ្យោបាយសមស្របនិងការគាំទ្រផ្នែកស្ថាប័ន។
- **ផែនការជួយជនរងគ្រោះ :** ដោយមិនបានបង្ហាញ ប៉ុន្តែចាប់តាំងពីឆ្នាំ២០០៧ មានការរាយការណ៍ ថាមានរបាយការណ៍ព្រៀងដែលត្រូវការធ្វើបច្ចុប្បន្នកម្ម ដោយផ្អែកលើការប៉ាន់ប្រមាណពីតម្រូវការ[១១]។
- **សាវតារជំនួយជនរងគ្រោះ :** ប្រជាជនភាគច្រើននៅក្នុងសាធារណរដ្ឋប្រជាមានិតកុងហ្គោ មិនមានលទ្ធភាពទទួលបានសេវាកម្មផ្សេងៗ ដោយសារជម្លោះ ភាពក្រីក្រ និងការផ្លាស់ទី លំនៅ រដ្ឋាភិបាលមិនអាចដោះស្រាយពីតម្រូវការជាច្រើនបាន។ នៅតាមទីកន្លែងជាច្រើន លទ្ធភាពទទួល បានសេវាមានលំដាប់ពីមានកម្រិតកំណត់រហូតដល់លែងមាន និងមានការរារាំងបន្ថែមដោយសារចម្ងាយឆ្ងាយពេក តំបន់មិនបង្កលក្ខណៈងាយស្រួល និងថ្លៃ

### សូចនាករប្រទេស

- **រយៈពេលមានជម្លោះនិងការប្រើប្រាស់គ្រាប់មីន/កាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម:** ការប៉ះពាល់ដោយសារគ្រាប់មីន គ្រាប់បែកចង្កោម និងសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមរួមទាំងយុទ្ធភ័ណ្ឌជាតិផ្ទុះគេបោះបង់ចោល (AXO) ក្នុងសាធារណរដ្ឋប្រជាមានិតកុងហ្គោ ជាលទ្ធផលពីជម្លោះប្រដាប់អាវុធ ដែលកើតមានជាតាំងពីឆ្នាំ១៩៩៦។ មានការប៉ះពាល់ដោយសារមីនតាំងពីពេលដំបូងដោយសារការប្រើប្រាស់កងកំលាំងបរទេស[១]។
- **ការប៉ាន់ប្រមាណពីការប៉ះពាល់:** គិតត្រឹមខែមិថុនា ឆ្នាំ២០០៨ គេសង្ស័យថាប្រហែលជាមានតំបន់សង្ស័យគ្រោះថ្នាក់ ១,៨៩៣ កន្លែង ប៉ុន្តែមិនមានព័ត៌មានពីទំហំ របស់វា និងចំនួនប្រជាជនដែលរងគ្រោះទេ[២]។
- **សន្ទស្សន៍អភិវឌ្ឍធនធានមនុស្ស :** ដោយនៅចំណាត់ថ្នាក់ទី១៦៨ ក្នុងចំណោមប្រទេសចំនួន១៧៩ សាធារណរដ្ឋប្រជាមានិតកុងហ្គោ មានការអភិវឌ្ឍធនធានមនុស្សនៅទាប (ធៀបនឹងឆ្នាំ២០០៤ មានចំណាត់ថ្នាក់ទី១៦៨ ក្នុងចំណោមប្រទេសចំនួន១៧៧)[៣]
- **ចំណូលជាតិសរុប (តាមវិធីសាស្ត្រ អាទ្លស) :** មានចំនួន ១៥០ ដុល្លា អាមេរិក—ចំណាត់ថ្នាក់ទី២០៩ក្នុងចំណោមតំបន់/ប្រទេសចំនួន២១០ (ប្រៀបធៀបឆ្នាំ២០០៤ មានចំនួនត្រឹមតែ ១០៩ ដុល្លាអាមេរិកប៉ុណ្ណោះ)[៤]
- **អត្រាគ្មានការងារធ្វើ :** មិនមានតួលេខ ប៉ុន្តែជាទូទៅត្រូវបានអះអាងថាមានប្រហែល ៨០%[៥]
- **ធនធានខាងក្រៅសម្រាប់ថែទាំសុខភាពគិតជាភាគរយនៃចំណាយសរុប:** ២៨.៨% (ប្រៀបធៀបនឹងឆ្នាំ២០០៤ មានចំនួន ១៩.៤%)[៦]
- **ចំនួនអ្នកថែទាំសុខភាពអាជីព:** ៦នាក់ក្នុងចំណោមមនុស្សចំនួន១០,០០០នាក់[៧]។
- **ស្ថានភាពអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ :** មិនមែនជាប្រទេសហត្ថលេខី គិតរហូតមកដល់ត្រឹមថ្ងៃទី១ ខែសីហា ឆ្នាំ២០០៩[៨]។
- **ថវិកាចំណាយលើវិស័យពិការភាព :** អត់មានតួរលេខ
- **ការវាស់វែងអំពីភាពក្រីក្រ និង ការអភិវឌ្ឍន៏:** តាមការរាយការណ៍ថា ក្នុងសាធារណរដ្ឋប្រជាមានិតកុងហ្គោមនុស្សជាង១,០០០នាក់ បានស្លាប់ជារៀងរាល់ថ្ងៃដោយសារតែសង្គ្រាម ដែលរួមមានជម្ងឺនិងហិង្សា[៩]។ ចាប់តាំងពីកើតមានជម្លោះមក តាមការប៉ាន់ស្មាន មានមនុស្សប្រមាណ៤លាននាក់ បានស្លាប់ដោយសារអំពើហិង្សា ភាពអត់ឃ្លាន និងជម្ងឺបណ្តាលពីជម្លោះ និង ២.៥លាននាក់អត់ទីជំរក។ សាធារណរដ្ឋប្រជាមានិតកុងហ្គោ មានធនធានធម្មជាតិដ៏មហិមា ប៉ុន្តែការដកហូតធនធានទាំងនេះ មិនបានផ្តល់ប្រយោជន៏ដល់ប្រជាជនភាគច្រើនឡើយ។ ជម្លោះជាបន្តបន្ទាប់ និងការស្ទាក់ស្ទើររបស់វិនិយោគិនបរទេស ព្រមទាំងភាពយឺតយ៉ាវផ្នែកសេដ្ឋកិច្ចក្នុងឆ្នាំ២០០៨ បានបន្តធ្វើឱ្យកាន់តែយ៉ាប់យ៉ឺនឡើងដល់សេដ្ឋកិច្ចដែលអន់ខ្សោយរួចទៅហើយ។ អង្គការមួយចំនួនប៉ាន់ប្រមាណថា ៨០%នៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ហើយអត្រាមរណភាព គឺនៅក្រោមអាយុ៤២ឆ្នាំ[១០]។

ចំណាយ។ សេវាកម្មភាគច្រើន ផ្ដល់ដោយអង្គការដែលធ្វើការ ដើម្បីកាត់បន្ថយស្ថានភាពសង្គ្រោះបន្ទាន់។ ប៉ុន្តែការផ្ទុះឡើងនូវជម្លោះឥតស្រាកស្រាន បានប្រែក្លាយភាពរីកចំរើនដែលមានកន្លងមក និងបានបង្កើនឱ្យមានតម្រូវការជាច្រើន ខណៈដែលអង្គការមួយចំនួនប្រឈមមុខនឹងបញ្ហាថវិកា។ ដោយសារជាក្រុមមួយក្នុងចំណោមក្រុមមនុស្សងាយរងគ្រោះ អ្នកនៅរស់រានមានជីវិតពីគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះសល់ពីសង្គ្រាម និងជនពិការផ្សេងទៀត បានទទួលសេវាកម្មមួយចំនួននៅចន្លោះឆ្នាំ២០០៥-២០០៩ ទោះបីជាផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់សាធារណរដ្ឋប្រជាមានិតកុងហ្គោ បានយកវិធានការផ្សេងៗដើម្បីជួយជនពិការមកអនុវត្តក៏ដោយ។ រដ្ឋាភិបាលបានទទួលស្គាល់ថា ខ្លួនខ្វះមធ្យោបាយ និងសមត្ថភាពដើម្បីធ្វើឱ្យមានការរីកចំរើនចំពោះជំនួយជនរងគ្រោះ។ ប្រជាជនភាគច្រើនលើសលុប មិនមានលទ្ធភាពទទួលបានសេវាគាំពារសុខភាព ពីព្រោះខ្វះបុគ្គលិក ថ្នាំសង្កូវ និងឧបករណ៍ និងពីព្រោះគេត្រូវចំណាយលុយ។ ការរង់ចាំចំពោះ ទម្រង់ការនៃការសង្គ្រោះបន្ទាន់ មានរយៈពេលយូរ (រហូតដល់ពីរថ្ងៃ)។ ទោះបីជាមានការវិនិយោគពីអន្តរជាតិច្រើនក៏ដោយ ប្រព័ន្ធសុខភាពត្រូវបាននិយាយថាហៀបនឹងដួលរលំនៅក្នុង ឆ្នាំ២០០៩[១២]។ វិស័យស្ដារកាយសម្បទា មិនបានផ្ដល់ធនធានគ្រប់គ្រាន់ ហើយមជ្ឈមណ្ឌលប្រតិបត្តិមួយចំនួន ពឹងផ្អែកទាំងស្រុងទៅលើការគាំទ្រពីអន្តរជាតិ ដែលបានកើនឡើងជាលក្ខណៈប្រព័ន្ធចាប់តាំងពីឆ្នាំ១៩៩៩។ ក្នុងឆ្នាំ២០០៥ រដ្ឋាភិបាលកត់សំគាល់ថា ស្ថានភាពសេដ្ឋកិច្ច និងនយោបាយធ្វើឱ្យមិនអាចទៅរួចសម្រាប់រដ្ឋាភិបាលចំពោះការគាំទ្រ ការបង្កើតការងារសម្រាប់អ្នកនៅរស់រានមានជីវិតពីគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងជនពិការផ្សេងៗទៀត[១៣]។ ស្ថានភាពនេះនៅតែអត់មានការប្រែប្រួលនៅក្នុងឆ្នាំ២០០៩។ ឱកាសជាច្រើនសម្រាប់ជំនួយផ្នែកចិត្តសាស្ត្រ ត្រូវបានកំណត់ដែនដល់គំរោងរបស់អង្គការមួយចំនួន ដែលធ្វើឡើងសម្រាប់អ្នកដែលបាក់ស្មារតីដោយសារជម្លោះ។ នៅក្នុងវង្វង់ប្រព័ន្ធគាំពារសុខភាព បុគ្គលិកបំរើសេវាសង្គមបានទទួលវគ្គបណ្ដុះបណ្ដាលក្នុងកម្រិតខ្ពស់ជាងមូលដ្ឋានបន្តិច។ ការអនុវត្តកម្មវិធីស្ដារលទ្ធភាពពលកម្មតាមសហគមន៍ ត្រូវបានរាំងស្ទះដោយសារខ្វះខាតថវិកា និង លទ្ធភាពទៅដល់សហគមន៍។ កម្មវិធីនេះ ត្រូវបានគិតស្រមៃថាជាមធ្យោបាយដ៏សំខាន់ឆ្ពោះទៅអនុវត្តជំនួយជនរងគ្រោះ។ ខណៈដែលជនពិការ ត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញដែលចូលជាធរមាននៅក្នុងឆ្នាំ២០០៦ នៅមិនទាន់មានច្បាប់ជាក់លាក់ណាមួយត្រូវបានបង្កើតរហូតដល់ឆ្នាំ២០០៩។ មជ្ឈមណ្ឌលសម្របសម្រួលសកម្មភាពកំចាត់មីនសហប្រជាជាតិ (UNMACC) ទទួលខុសត្រូវចំពោះការប្រមូលទិន្នន័យពីជនរងគ្រោះ ប៉ុន្តែទិន្នន័យនៅតែមិនពេញលេញដោយសារការមិនបង្កលក្ខណៈងាយស្រួលនៅតំបន់មួយចំនួន និងកង្វះសមត្ថភាពនៅមជ្ឈមណ្ឌលសម្របសម្រួលសកម្មភាពកំចាត់មីនសហប្រជាជាតិ(UNMACC)[១៤]។

**ជំនួយបានមកពីអ្នកផ្ដល់ជំនួយផ្សេងៗគ្នា**



# ភាពជឿនលឿនពីជំនួយជនរងគ្រោះនៅមូលដ្ឋាន

## *សាវតារអ្នកផ្តល់ចំលើយ*[១៥]

គិតត្រឹមខែកក្កដា ឆ្នាំ២០០៩ អ្នកនៅរស់រានមានជីវិតចំនួន៤៥នាក់ ដែលមានអាយុចន្លោះពី១២-៧០ឆ្នាំ បានឆ្លើយតបចំពោះបញ្ជីសំណួរមួយស្តីពីវឌ្ឍនភាពនៃជំនួយជនរងគ្រោះនៅក្នុងសាធារណរដ្ឋប្រជាមានិតកុងគោតាំងពីឆ្នាំ២០០៥ ដែលមាន៧៨% ជាមនុស្សជំទង់ និង២២% ជាកុមារ។ ប្រហែលជា៨៧%នៃអ្នកផ្តល់ចម្លើយជាបុរស និង៤៦%ជាមេគ្រួសារ។ យ៉ាងហោចណាស់ ២២% មិនបានទទួលការអប់រំ។ យ៉ាងហោចណាស់ ២៤%នៃអ្នកផ្តល់ចម្លើយ អត់មានការងារធ្វើមុនពេលជួបឧប្បត្តិហេតុផ្ទុះមីន ហើយតួរលេខនេះ បានកើនឡើងបន្តិចរហូតដល់៣១% បន្ទាប់ពីឧប្បត្តិហេតុ។ ក្នុងចំណោមអ្នកផ្តល់ចម្លើយដែលឆ្លើយសំណួរ ៩២%គិតថាប្រាក់ចំណូលរបស់ពួកគេមិនគ្រប់គ្រាន់។ ក្រុមអ្នកផ្តល់ចម្លើយច្រើនបំផុត (៣៨%) រស់នៅក្នុងភូមិមួយដែលមានផ្តល់សេវាកម្មខ្លះៗ ៣៥%រស់នៅក្នុងរាជធានី ១៦%រស់នៅតាមតំបន់ដាច់ស្រយាដែលគ្មានសេវា និងនៅសល់១១%រស់នៅតាមទីក្រុងធំៗ។ ឧប្បត្តិហេតុជាច្រើន បានកើតឡើងនៅចន្លោះឆ្នាំ១៩៦៧-២០០៩ ដែលច្រើនបំផុតនៅចន្លោះឆ្នាំ១៩៩០-២០០០ ដែលស្រដៀងគ្នាទៅនឹងការរាយការណ៍របស់ UNMACC ស្តីពីជនរងគ្រោះ។ UNMACC បានគូសបញ្ជាក់ថា ភាគច្រើននៃជនរងគ្រោះជាបុរស និងពួកគេភាគច្រើនជាជនស៊ីវិល។

## *ការរកឃើញទូទៅ*

ជារួម អ្នកផ្តល់ចម្លើយជាច្រើនមើលឃើញថា មិនមានការរីកចំរើនទេពាក់ព័ន្ធនឹងការផ្តល់សេវាជំនួយជនរងគ្រោះនៅក្នុងសាធារណរដ្ឋប្រជាមានិតកុងគោរវាង ឆ្នាំ២០០៥-២០០៩។ គ្មានអ្នកផ្តល់ចម្លើយណាម្នាក់និយាយថា ពួកគេបានទទួលសេវាកម្មក្នុងឆ្នាំ២០០៩ច្រើនជាង ឬប្រសើរជាងក្នុងឆ្នាំ២០០៥ទេ។ មានអត្រាមិនឆ្លើយតបខ្ពស់ចំពោះសំណួរដែលសួរអំពីស្ថានភាពទូទៅនៃការគាំពារសុខភាព ការស្តារកាយសម្បទា ការគាំទ្រចិត្តសង្គម ការបញ្ចូលផ្នែកសេដ្ឋកិច្ច និងច្បាប់ និងគោលនយោបាយសាធារណៈ ដោយឡែក ស្ទើរតែអ្នកផ្តល់ចម្លើយទាំងអស់ បានឆ្លើយសំណួរស្ទង់មតិទាំងអស់ស្តីពីសេវាកម្ម (៩៦% បានបំពេញគ្រប់ចម្លើយទាំងអស់ចំពោះសូចនាករជាក់លាក់នៃវឌ្ឍនភាព)។ ក្នុងន័យនេះ ប្រហែលជាមានសារៈសំខាន់ផ្នែកស្ថិតិ ដែលទំនងជាគូសបញ្ជាក់ថា បើមិនមានចម្លើយពាក់ព័ន្ធទេ (ចម្លើយ "ស្ថិតនៅដដែល" មិនអាចពិពណ៌នាឱ្យបានត្រឹមត្រូវពីអវត្តមានបន្តបន្ទាប់នៃសេវាកម្ម) ក៏ប្រហែលជាអាចគូសបញ្ជាក់ពីមូលហេតុរាំងស្ទះ ព្រមជាមួយកង្វះខាតសេវាកម្ម និងកង្វះខាតការធ្វើឱ្យប្រសើឡើងនៅក្នុងគ្រប់វិស័យ។

អ្នកផ្តល់ចម្លើយភាគច្រើន (៦៧%) គិតថាសេវាកម្មសម្រាប់អ្នកនៅរស់រានមានជីវិតជាកុមារ "មិនដែលទទួល" បានរៀបចំឱ្យស៊ីគ្នាជាមួយតម្រូវការរបស់ពួកគេ ៦៩%រាយការណ៍ថា បើប្រៀបធៀបជា មួយអ្នកនៅរស់រានមានជីវិតជាបុរស សេវាកម្មសម្រាប់អ្នក នៅរស់រានមានជីវិតជាស្ត្រីគឺ "អត់មានតែម្តង" ចំណែក១១% បានរាយការណ៍ថា សេវាកម្មទាំងនោះមានលក្ខណៈ "ស្មើគ្នា"។

គ្មានអ្នកផ្តល់ចម្លើយណាម្នាក់ត្រូវបានស្ទង់មតិដោយអង្គការឬរដ្ឋាភិបាលកាលពីប្រាំឆ្នាំមុនទេ។ លទ្ធផលនេះ ប្រហែលជាបានអះអាងពីកង្វះខាតការប្រមូលទិន្នន័យជាលក្ខណៈប្រព័ន្ធដោយសារទីកន្លែងមិនបង្កលក្ខណៈងាយស្រួល កង្វះហេដ្ឋារចនាសម្ព័ន្ធ និងហេតុផលសន្តិសុខ។ UNMACC បានរាយការណ៍ថា ជនរងគ្រោះជាច្រើនមិនត្រូវបានរាយការណ៍ ហើយអង្គការ ពីរដែលគាំទ្រកិច្ចខិតខំប្រឹងប្រែងស្ទង់មតិ បានគូសបញ្ជាក់ច្រំដែល ថាខ្លួនមានការលំបាកណាស់ក្នុងការស្វែងរកទីកន្លែងរបស់អ្នកនៅរស់រានមានជីវិតពីគ្រាប់មី និងសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម ពីព្រោះពួកគេជាច្រើនរស់នៅក្នុងតំបន់ដាច់ស្រយា ឬបំលាស់ទីដោយសារជម្លោះ និងដោយសារវាត្រូវការពេលវេលាជាច្រើនថ្ងៃ ដើម្បីទៅជួបមនុស្សម្នាក់ដោយសារទំហំប្រទេសនិងផ្លូវលំបាក។ បន្ថែមពីនេះទៀតអ្នកនៅរស់រានមានជីវិតជាច្រើន មានស្ថានភាពល្អមុនឆ្នាំ២០០៥ និងប្រហែលជាត្រូវបានគេស្ទង់មតិនៅពេលនោះ។

## និន្នាការនៃសេវាសំរាប់ជួយជនរងគ្រោះចាប់ពីឆ្នាំ២០០៥




## *សង្គ្រោះបន្ទាន់និងការថែទាំបន្តផ្នែកវេជ្ជសាស្ត្រ*

ក្នុងចំណោមអ្នកដែលឆ្លើយតបទៅនឹងសំណួរថាតើសេវាគាំពារសុខភាពបានប្រសើរឡើងឬអត់ នៅដដែល ឬអាក្រក់ជាងមុនតាំងពីឆ្នាំ២០០៥ មាន២៤%និយាយថា ស្ថានភាពនោះនៅដដែរ និង១១%និយាយថា វាប្រែក្លាយទៅជាអាក្រក់ជាងមុន (៦៤%មិនបានឆ្លើយ)។ អ្នកផ្តល់ចម្លើយភាគច្រើន (៦៧%) និយាយថា កាលពីប្រាំឆ្នាំមុន អ្នកនៅរស់រានមានជីវិតពីគ្រាប់មីន និងសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម "មិនដែល" បានទទួលការគាំពារផ្នែកវេជ្ជសាស្ត្រតាមតម្រូវការរបស់ពួកគេឡើយ និង១១%ផ្សេងទៀតយល់ឃើញថា "ស្ទើរតែមិនមែន" ជាការពិត។ វឌ្ឍនភាពខ្លាំងបំផុត (ប៉ុន្តែមានតែ៩%) ត្រូវបានមើលឃើញអំពីការកើនឡើងនូវបុគ្គលិកសង្គ្រោះបឋម។ អ្នកផ្តល់ចម្លើយពីរនាក់ផ្សេងទៀត (៤%) ជឿថាមណ្ឌលសុខភាពមានក្រុមការងារ ដែលមានលក្ខណៈពេញលេញជាងពីមុន។

ចម្លើយដែលមិនសូវមានហេតុផលទាំងនេះ ស៊ីគ្នាជាមួយស្ថានភាពរបស់មណ្ឌលសុខភាពដ៏ល្បីល្បាញមួយ នៅក្នុងសាធារណរដ្ឋប្រជាមានិតកុងហ្គោ។ យោងតាមរបាយការណ៍រីកចំរើន Zagreb ឆ្នាំ២០០៥ សាធារណរដ្ឋប្រជាមានិតកុងហ្គោមានមន្ទីរពេទ្យ៤០០[១៦]។ ក្នុងឆ្នាំ២០០៦ អង្គការសុខភាពពិភពលោក ពិពណ៌នាមន្ទីរពេទ្យចំនួន២០០ ឬស្មើពាក់កណ្តាលថា "មានហានិភ័យ"[១៧]។ នៅឆ្នាំដដែល UNMACC រាយការណ៍ថាភាគច្រើននៃអ្នកនៅរស់រានមានជីវិត "ត្រូវបានទុកចោលដោយសារការពិតដែលថា ប្រព័ន្ធសុខាភិបាលជាតិមិនទាន់មានសមត្ថភាពផ្តល់ជំនួយនៅឡើយ"[១៨]។ ចាប់ពីឆ្នាំ២០០៦-២០០៩ មានការរាយការណ៍យ៉ាងទៀងទាត់ថា ការគាំពារសុខភាពលក្ខណៈសង្គ្រោះបន្ទាន់នៅក្នុងសាធារណរដ្ឋប្រជាមានិតកុងគោ នៅតែមិនទាន់សមស្រប ទោះបីជាមានការវិនិយោគពីអន្តរជាតិជាបន្តបន្ទាប់។ ជារួម វិស័យនេះមិនអាចលៃលកជាមួយវិបត្តិដែលចេះតែបន្ត និងការផ្គត់ផ្គង់ដែលតែងតែខ្វះខាតសម្ភារៈ និងបុគ្គលិកបានឡើយ។ គេនិយាយថា មានតែវេជ្ជបណ្ឌិតជំនាញវះកាត់១០នាក់ប៉ុណ្ណោះ នៅក្នុងប្រទេសទាំងមូលក្នុងឆ្នាំ២០០៦។ អស្ថេរភាព បានបណ្តាលឱ្យមានការលួចយកឧបករណ៍ពេទ្យ។ នៅតាមទីកន្លែងជាច្រើនដែលសេវាសុខភាពសាធារណៈបានដួលរលំ ជម្លោះដែលបន្តឥតស្រាកស្រាន បានធ្វើឱ្យរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងជួយសង្គ្រោះរបស់អន្តរជាតិ ហើយទន្ទឹមពេលជាមួយគ្នានេះដែរ បានធ្វើឱ្យចំនួនមនុស្សដែលត្រូវការសេវាគាំពារសុខភាពកើនឡើង[១៩]។

## *ការស្តារនីតិសម្បទា*

ការរីកចំរើនបំផុតត្រូវបានរាយការណ៍ថាស្ថិតក្នុងវិស័យស្តារកាយសម្បទា និងឧបករណ៍ទ្រទ្រង់រាងកាយសប្បនិម្មិត។ យ៉ាណាក៏ដោយ អ្នកផ្តល់ចម្លើយភាគច្រើន (៦៤%) រាយការណ៍ថា អ្នកនៅរស់រាន មានជីវិត "មិនដែល" បានទទួលសេវាស្តារកាយសម្បទាឡើយ កាលពី៥ឆ្នាំមុន។ ភាពប្រសើរឡើងក្នុងសេវាកម្មដោយសារបុគ្គលិក ទទួលការបណ្តុះបណ្តាលល្អជាងមុន និងឧបករណ៍ទ្រទ្រង់រាងកាយ សប្បនិម្មិតមានគុណភាពល្អជាងមុនត្រូវបានកត់សំគាល់ដោយអ្នកផ្តល់ចម្លើយចំនួន២២%។ ប្រហែល២០%គិតថា មណ្ឌលស្តារលទ្ធភាពពលកម្ម មានក្រុមការងារពេញលក្ខណៈច្រើនជាងមុន។ ១៦%យល់ឃើញថា វាមានភាពងាយស្រួលជាងមុន ក្នុងការទទួលបានឧបករណ៍បន្លាស់ និងនិយាយថា សេវាស្តារលទ្ធភាពពលកម្មអាចលៃលករកបានច្រើនជាងមុន។ មានតែ១៣% កត់សំគាល់ឃើញថាមានការកើនឡើងការជួសជុលដោយឥតគិតថ្លៃ។ មិនមានអ្នកផ្តល់ចម្លើយណាម្នាក់ ជឿថា រដ្ឋាភិបាលបានផ្តល់ការគាំទ្រច្រើនជាងមុនដល់ ការស្តារកាយសម្បទា។

**បំពេញតំរូវការរបស់ជនរងគ្រោះឆ្នាំ២០០៥**




ភាពរីកចំរើនដែលចុះឈ្មោះដោយអ្នកផ្តល់ចម្លើយមួយចំនួន ទំនងអាចចាត់ទុកថាជាឥទ្ធពលនៃការគាំទ្ររបស់ ICRC ទៅដល់មណ្ឌលកែទម្រង់រាងកាយ។ ចាប់តាំងពីឆ្នាំ២០០៥ ICRCបានបង្កើនការគាំទ្ររបស់ខ្លួនពី៣-៥មណ្ឌល ដោយចេញថ្លៃឱ្យអ្នកជម្ងឺ ផ្គត់ផ្គង់សម្ភារៈនាំចូល និងផ្តល់វគ្គបណ្តុះបណ្តាល[២០]។ ខណៈដែលក្រសួងសុខាភិបាលទទួលខុសត្រូវវិស័យស្តារលទ្ធភាពពលកម្ម ខ្លួនមិនបានគ្រប់គ្រងមជ្ឈមណ្ឌលស្តារកាយសម្បទាចន្លោះឆ្នាំ២០០៥-២០០៩។ PNRBC នៃក្រសួងសុខាភិបាល មិនមានធនធានគ្រប់គ្រាន់ដើម្បីប្រតិបត្តិឱ្យមានប្រសិទ្ធភាពចាប់តាំងពីបង្កើតនៅឆ្នាំ២០០២មក។ មជ្ឈមណ្ឌលជាច្រើន ត្រូវគ្រប់គ្រងជំនួសដោយអង្គការក្រៅរដ្ឋាភិបាល អង្គការសាសនា ឬក្រុមហ៊ុនឯកជនផ្សេងៗ ដែលមិនមានមធ្យោបាយផ្នែកហិរញ្ញវត្ថុដើម្បីផ្តល់សេវាកម្មឥតគិតថ្លៃ។ មជ្ឈមណ្ឌលជាច្រើន អត់មានដំណើរការ មិនអាចផលិតឧបករណ៍សម្រួលដល់ការចល័តបាន ឬត្រូវការវគ្គបណ្តុះបណ្តាលបុគ្គលិក[២១]។

## *ការគាំទ្រផ្លូវចិត្ត និង សមាហរណកម្មសង្គម*

អ្នកផ្តល់ចម្លើយភាគច្រើន (៨៤%) រាយការណ៍ថា អ្នកនៅរស់រានមានជីវិត "មិនដែល" បានទទួលការគាំទ្រផ្នែកចិត្តសាស្ត្រ និងការបញ្ចូលផ្នែកសេដ្ឋកិច្ចកាលពីប្រាំឆ្នាំមុន ដែលក្នុងនោះ៤%និយាយថា "ពេលខ្លះ" ២%និយាយថា "ស្ទើរតែមិនដែល" និង៩%មិនច្បាស់។ មិនមានអ្នកផ្តល់ចម្លើយណាម្នាក់រាយការណ៍ពីការកើនឡើងនូវចំនួនសេវាកម្ម ចំនួនបុគ្គលិកបំរើសេវាសង្គម ឬពីលទ្ធភាពគាំទ្រអ្នកដែលប្រហាក់ប្រហែលគ្នាក្នុងរយៈពេលប្រាំឆ្នាំ។ ចម្លើយដែលមានការយល់ព្រមច្រើនបំផុតពីអ្នកផ្តល់ចម្លើយ (១៦%) បានចាត់ទុកអារម្មណ៍ដែលទទួលបានសិទ្ធិអំណាចច្រើនជាងមុនថាជាលក្ខណៈបុគ្គល។ ៩%ផ្សេងទៀតឱ្យដឹងថាបានចូលរួមខ្លាំងក្នុងការងារគាំទ្រចិត្តសង្គមសម្រាប់អ្នកដទៃ។ ប្រមាណ៤% មានអារម្មណ៍

ថាបានចូលរួមច្រើនជាងមុនក្នុងសកម្មភាពសហគមន៍ ឬជឿថាមានឧបសគ្គតិចជាងមុន ក្នុងការស្វែងរកការប្រឹក្សាយោបល់ពីចិត្តសាស្ត្រ។ មិនមានអ្នកផ្តល់ចម្លើយណាម្នាក់ជឿជាក់ថា អ្នកនៅរស់រានមានជីវិតត្រូវបានចាត់ទុកថាជា "ករណីសប្បុរសធម៌" ទេឬថា រដ្ឋាភិបាលបានផ្តល់ការគាំទ្រច្រើនជាងមុនដល់សកម្មភាពចិត្តសង្គម។

ចម្លើយអ្នកនៅរស់រានមានជីវិត ស្របគ្នានឹងការរាយការណ៍ផ្សេងទៀតពាក់ព័ន្ធនឹងការបន្តការខ្វះខាតខាងសេវាកម្ម។ នៅក្នុងឆ្នាំ២០០៥ សាធារណរដ្ឋប្រជាមានិតកុងហ្គោ កត់សំគាល់ពីកង្វះខាតការទទួលខុសត្រូវផ្នែកស្ថាប័ន និងបទដ្ឋានដើម្បីផ្តល់ការគាំទ្រផ្នែកចិត្តសង្គមដល់អ្នកនៅរស់រានមានជីវិតពីគ្រាប់មីននិងសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម[២២]។ ការគាំពារផ្នែកចិត្តសង្គមដល់ជនពិការ ឬមនុស្សដែលបាក់ស្មារតីដោយសារសង្គ្រាមស្ទើរតែលែងមាន។ មិនមានគេដឹងថាមានកម្មវិធីគាំទ្រផ្នែកចិត្តសាស្ត្រសម្រាប់អ្នកនៅរស់រានមានជីវិត ទោះបីជាចំណេះដឹងមូលដ្ឋានផ្នែកគាំពារផ្នែកផ្លូវចិត្តរបស់បុគ្គលិកស្តារលទ្ធភាពពលកម្ម និងគាំពារសុខភាពមួយចំនួន នៅមានកម្រិតក៏ដោយ[២៣]។ ក្នុងឆ្នាំ០០៧ សាធារណរដ្ឋប្រជាមានិតកុងហ្គោ បានទទួលស្គាល់បញ្ហាប្រឈមពាក់ព័ន្ធនឹងការបង្កើតក្របខ័ណ្ឌសម្រាប់ការគាំទ្រផ្នែកចិត្តសាស្ត្រ និង ការដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រស្តារលទ្ធភាពពលកម្មតាមសហគមន៍[២៤]។ សេវាកម្មគាំទ្រផ្នែកចិត្តសាស្ត្រដែលនៅមានកម្រិតរបស់អង្គការ បានជួយដោះស្រាយបញ្ហាស្លុតស្មារតីដោយសារសង្គ្រាម និងចាប់ផ្តើមផ្តោតខ្លាំងបន្ថែមទៀតទៅលើបញ្ហាអំពើហិង្សាផ្លូវភេទ និងការរំលោភសេពសន្ថវៈ ដែលជាអាវុធសង្គ្រាម[២៥]។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៨ សាធារណរដ្ឋប្រជាមានិតកុងហ្គោបានរាយការណ៍ថា ខ្លួនមានគោលបំណងគាំទ្រការបង្កើតអង្គការសម្រាប់អ្នកនៅរស់រានមានជីវិត ប៉ុន្តែមិនមានការអភិវឌ្ឍបន្ថែមផ្សេងទៀតត្រូវបានកំណត់[២៦]។

## សមាហរណកម្មសេដ្ឋកិច្ច

មិនមានអ្នកផ្តល់ចម្លើយណាម្នាក់ មើលឃើញថាមានការរីកចំរើនក្នុងឱកាសបញ្ចូលផ្នែកសេដ្ឋកិច្ចចាប់តាំងពីឆ្នាំ២០០៥។ អ្នកផ្តល់ចម្លើយភាគច្រើន (៨៤%) ជឿថា អ្នកនៅរស់រានមានជីវិត មិនដែលទទួលបានធ្វើសមាហរណកម្មសេដ្ឋកិច្ចតាមតម្រូវការរបស់ពួកគេ ចំណែក៤%ទៀតនិយាយថា "ស្ទើរតែមិនដែល" (អ្នកនៅសល់មិនច្បាស់)។ ក្រៅពីអ្នកផ្តល់ចម្លើយបួននាក់ (៩%) ដែលជឿជាក់ថា ការរើសអើងនៅក្នុងវិស័យការងារបានធ្លាក់ចុះ ដោយមិនមានការរីកចំរើនណាមួយ ត្រូវបានរាយការណ៍ពីសមាហរណកម្មសេដ្ឋកិច្ចឡើយ។

ចម្លើយទាំងនេះ គួរឱ្យខកចិត្ត ប៉ុន្តែមិនមានការភ្ញាក់ផ្អើលទាក់ទងនឹងស្ថានភាពសេដ្ឋកិច្ចដែលមិនអាចទទួលយកបាន និងអត្រាអត់ការងារធ្វើដ៏ខ្ពស់ (រហូតដល់៨០%)ទេ។ ក្នុងឆ្នាំ២០០៥ សាធារណរដ្ឋប្រជាមានិតកុងហ្គោ កត់សំគាល់ឃើញថា ស្ថានភាពនេះនៅក្នុងប្រទេស បានរារាំងខ្លួនមិនឱ្យគាំទ្រឱកាសសមាហរណកម្មសេដ្ឋកិច្ចសម្រាប់អ្នកនៅរស់រានមានជីវិត និងបន្តទទួលស្គាល់បញ្ហានេះអំឡុងពេលពិនិត្យមើលឡើងវិញ។ ក្នុងឆ្នាំ២០០៩ សកម្មភាពបញ្ចូលផ្នែកសេដ្ឋកិច្ច បានបន្តក្នុងស្ថានភាពស្ទើរលែងមានក្នុងសាធារណរដ្ឋប្រជាមានិតកុងគោ។ ភាពអត់មានឥណទានខ្នាតតូច ឬឱកាសប្រកបមុខជំនួយខ្នាតតូចសម្រាប់ជនពិការ ត្រូវបានដឹងថាកើតមានពិតប្រាកដ។ មូលនិធិទាំងឯកជន និងរដ្ឋដែលមានកម្រិតកំណត់ ត្រូវបានផ្តល់ដល់មជ្ឈមណ្ឌលបណ្តុះបណ្តាលសម្រាប់ជនពិការ ដែលកើតមានក្នុងមណ្ឌលតាមទីប្រជុំជនមួយចំនួន។ សមត្ថភាពរបស់មណ្ឌលទាំងនេះនៅមានកម្រិតនៅឡើយ[២៧] ហើយអ្នកនៅរស់រានមានជីវិតពីគ្រាប់មីន និងកាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមមិនត្រូវបានរាយការណ៍ថាបានទាក់ទងស្នើសុំ សេវាកម្ម ផ្នែកសេដ្ឋកិច្ច ឬជំនាញបែបណាមួយឡើយ[២៨]។

## ច្បាប់ និងគោលនយោបាយសាធារណៈ

អ្នកផ្តល់ចម្លើយភាគច្រើនលើសលុប (៩៣%) រាយការណ៍ថា កាលពីប្រាំឆ្នាំមុន សិទ្ធិអ្នកនៅរស់រានមានជីវិត មិនដែលត្រូវបានអនុវត្តតាមរយៈការអនុវត្តច្បាប់ និងគោលនយោបាយផ្សេងៗ (៧%មិនច្បាស់)។ ៩%នៃអ្នកផ្តល់ចម្លើយគិតថា ច្បាប់ថ្មី និងគោលនយោបាយទាក់ទងនឹងអ្នកនៅរស់រានមានជីវិត ត្រូវបានបង្កើត ប៉ុន្តែមិនមាននរណាម្នាក់រាយការណ៍ពីភាពរីកចំរើនស្តីពីការអនុវត្តច្បាប់ឡើយ។ អ្នកផ្តល់ចម្លើយ២-៣នាក់ (៧%) រាយការណ៍ថា ការរើសអើងប្រឆាំងនឹងអ្នកនៅរស់រានមានជីវិត បានធ្លាក់ចុះ ចំណែក១១%រាយការណ៍ថា មានការប្រើប្រាស់ពាក្យមិនគប្បីតិចជាងមុនទៅលើជនពិការ។ ទោះជាយ៉ាងនេះក្តី ភាពមិនមានការកើនឡើងពីការយល់ដឹងជាសាធារណៈអំពីសិទ្ធិរបស់អ្នកនៅរស់រាន

មានជីវិត ឬជនពិការ ត្រូវបានគេសង្កេតឃើញ ហើយគ្មានអ្នកផ្ដល់ចម្លើយណាម្នាក់ បានរាយការណ៍ថា ពួកគេមានលទ្ធភាពទទួលបានព័ត៌មានអំពីសេវាកម្ម ឬសិទ្ធិរបស់ពួកគេច្រើនជាងមុនឡើយ។

ការប៉ាន់ប្រមាណពីវឌ្ឍនភាពអវិជ្ជមានរបស់អ្នកផ្ដល់ចម្លើយ ក្នុងដំណើរការធានាសិទ្ធិរបស់អ្នកនៅរស់រានមានជីវិត ត្រូវគ្នានឹងតម្រូវការសុំឱ្យមានការអនុវត្តច្បាប់ដែលមានស្រាប់ និងសុំឱ្យមានការណែនាំពីច្បាប់ពិការភាពជាក់លាក់។ ពិការភាព ត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ២០០៦ ហើយចាប់តាំងពីឆ្នាំ២០០៣ សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ បានបញ្ជាក់ជាញឹកញាប់ថា ខ្លួនកំពុងរៀបចំពង្រាង ឬក្នុងដំណើរការបង្រាងច្បាប់ពិការភាព ដែលនឹងឆ្លើយតបចំពោះតម្រូវការរបស់អ្នកនៅរស់រានមានជីវិតពីគ្រាប់មីន និងកាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម។ ក្នុងឆ្នាំ២០០៨ ប្រទេសនេះបានរាយការណ៍ថា កង្វះខាតច្បាប់ស្ដីពីពិការភាព ជាឧបសគ្គ ហើយថាកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការយល់ដឹង ត្រូវបានអនុវត្ត[២៩]។ សមាគមក្នុងស្រុកដើម្បីជនពិការក្នុងខេត្ត Kinshasa ចាប់ផ្ដើមធ្វើការលើសេចក្ដីព្រាងច្បាប់ពិការភាព ដោយផ្អែកលើរដ្ឋធម្មនុញ្ញ[៣០]។ ចន្លោះឆ្នាំ ២០០៥-២០០៩ របាយការណ៍ស្ដីអំពីការរើសអើងនិងការមិនអនុវត្តច្បាប់របស់រដ្ឋាភិបាល ដែលមានស្រាប់ឱ្យមានប្រសិទ្ធភាពជាបញ្ហាទូទៅ។ សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោចាប់តាំងពីឆ្នាំ២០០៧ បានរាយការណ៍ថាខ្លួនកំពុងស្ថិតក្នុងដំណើរការព្រមព្រៀង ចំពោះអនុសញ្ញាសហប្រជាជាតិស្ដីពីសិទ្ធិជនពិការ ដែលគ្មានលទ្ធផលគិតរហូតដល់ថ្ងៃទី១ ខែសីហា ឆ្នាំ២០០៩[៣១]។ មិនមានតំណាងរដ្ឋាភិបាលណាម្នាក់អាចផ្ដល់អនុសាសន៍លើលទ្ធផលរកឃើញនេះទេ។

## ការសម្រេចបានលើដំណើរការជួយជនរងគ្រោះ

| ឆ្នាំ | ទម្រង់ J និយាយពីការជួយដល់ជនរងគ្រោះ | សេចក្ដីថ្លែងការណ៍នៅ ឯកិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍ស្ដីពីការជួយជនរងគ្រោះ | សេចក្ដីថ្លែងការណ៍នៅ ឯកិច្ចប្រជុំរដ្ឋភាគីស្ដីពីការជួយជនរងគ្រោះ | អ្នកជំនាញផ្នែកជំនួយជនរងគ្រោះ | អ្នករស់រានជីវិតពីមីនជាគណៈប្រតិភូ |
|---|---|---|---|---|---|
| ២០០៥ | មាន | គ្មាន | មាន | គ្មាន | គ្មាន |
| ២០០៦ | មាន | មាន | មាន | មាន | គ្មាន |
| ២០០៧ | មាន | មាន | មាន | មាន | គ្មាន |
| ២០០៨ | មាន | គ្មាន | មាន | មាន | គ្មាន |
| ២០០៩ | មាន | គ្មាន | អត់មានទិន្នន័យ | គ្មាន | គ្មាន |

ដោយសារជាប្រទេសមួយដែលមានធនធានសង្គម និងសុខាភិបាលតិចតួច មានសេដ្ឋកិច្ចខ្សោយខ្លាំង និងជម្លោះជាបន្តបន្ទាប់ មិនគួរឱ្យភ្ញាក់ផ្អើលនោះទេដែលថា មានការរីកចំរើនតិចតួចនៅក្នុងជំនួយជនរងគ្រោះនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ចន្លោះឆ្នាំ២០០៥-២០០៩។ ខណៈដែលសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោទទួលស្គាល់ពីសារៈសំខាន់នៃជំនួយជនរងគ្រោះ និងការធ្វើសមាហរណកម្មវិស័យពិការភាព ប្រទេសនេះបានបញ្ជាក់ថា ភាពរីកចំរើនមិនអាចធ្វើទៅបានទេដោយសារតែគ្មានថវិកា និងជំនួយបច្ចេកទេស និងដោយសារតែក្របខ័ណ្ឌច្បាប់នៅខ្សោយ[៣២]។ ការវាយតំលៃឯករាជ្យឆ្នាំ២០០៨មួយទៅលើមជ្ឈមណ្ឌលសកម្មភាពកំចាត់មីន UNMACC បានកត់សំគាល់យ៉ាងខ្លីថាមានការខ្វះខាតយ៉ាងធ្ងន់ធ្ងរនូវសេវាជំនួយសង្គ្រោះ[៣៣]។

ក្នុងនាមជាប្រទេសមួយក្នុងចំណោមប្រទេសជារដ្ឋភាគីទាំង២៦ ដែលមានចំនួនអ្នកនៅរស់រានមានជីវិតពីគ្រាប់មីនដ៏ច្រើន និងមានការទទួលខុសត្រូវដ៏ធំ និង "ដែលត្រូវទទួលភារកិច្ចច្រើនជាងគេ ប៉ុន្តែក៏មានតម្រូវការ និងការរំពឹងលើជំនួយដ៏ខ្លាំបំផុតដែរនោះ" សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ បានបង្ហាញពីគោលបំណងឆ្នាំ២០០៥-២០០៩របស់ខ្លួនក្នុងឆ្នាំ២០០៥ និងត្រួតពិនិត្យមើលឡើងវិញនៅក្នុងឆ្នាំ២០០៦។ គោលបំណងដែលមានដាក់ពេលវេលាសុទ្ធតែត្រូវសម្រេចឱ្យបាននៅក្នុងឆ្នាំ២០០៩ ចំណែកឯគោលបំណងជាច្រើនជាក់លាក់ផ្សេងៗទៀត មិនសូវជាក់លាក់។ មិនមានផែនការណាមួយត្រូវបានបង្ហាញទេ ទោះបីជាមានការរាយការណ៍តាំងពីឆ្នាំ២០០៧ថា ផែនការពង្រាងមួយបានរៀបចំរួចរាល់ហើយក៏ដោយ។ ក្នុងឆ្នាំ២០០៨ គេនិយាយថា ការប៉ាន់ប្រមាណពីតម្រូវការបន្ថែមមួយ ចាំបាច់ត្រូវធ្វើឡើងដើម្បីបំពេញផែនការ —ការបំពេញនេះ បានបន្ត

រហូតដល់ឆ្នាំ២០០៩[៣៤]។ មកត្រឹមឆ្នាំ២០០៩ សាធារណរដ្ឋប្រជាមានិតកុងហ្គោ រាយការណ៍ថាជំនួយជនរងគ្រោះបានឈប់ដំណើរការទាំងស្រុង ដោយសារតែលក្ខខ័ណ្ឌមិនល្អនៅក្នុងប្រទេស[៣៥]។

ក្នុងឆ្នាំ២០០៥ បេសកកម្មវាយតំលៃរបស់សេវាកម្មសកម្មភាពកំចាត់មីនសហប្រជាជាតិ (UNMAS) ចំពោះសាធារណរដ្ឋប្រជាមានិតកុងហ្គោ បានឱ្យអនុសាសន៍ថា UNMACC និងរដ្ឋាភិបាលត្រូវធ្វើការរួមគ្នាក្នុងការពង្រាងយុទ្ធសាស្រ្តជំនួយជនរងគ្រោះថ្នាក់ជាតិ និងកំណត់ជនបង្គោលដែលទទួលខុសត្រូវចំពោះជំនួយជនរគ្រោះ។ (UNMAS) កត់សំគាល់ឃើញថា បញ្ហានេះគួរតែនៅក្នុងរង្វង់ក្រសួងសង្គមកិច្ច និងគ្រួសារ[៣៦] ដែលជាស្ថាប័នទទួលខុសត្រូវផ្នែកពិការភាព។ ប៉ុន្តែមិនមានភស្តុងតាងពីក្រសួងនេះថាបានទទួលខុសត្រូវពីជំនួយជនរងគ្រោះ ហើយការទទួលខុសត្រូវជាច្រើននៅតែមិនច្បាស់លាស់នៅឡើយរហូតដល់ចុងឆ្នាំ២០០៧ នាយកមជ្ឈមណ្ឌល PNRBC នៃក្រសួងសុខាភិបាល ត្រូវបានប្រគល់តួនាទីជាជនបង្គោល។ ទោះជាយ៉ាងនេះក្តី អវត្តមានការគាំទ្រផ្នែកស្ថាប័នចំពោះជនបង្គោល បានរារាំងមិនឱ្យមានការរីកចំរើន ចំណែកកម្មវិធីវិញ មានធនធានមិនគ្រប់គ្រាន់ដើម្បីបំពេញតួនាទីរបស់ខ្លួនឱ្យមានប្រសិទ្ធិភាពទេ។

ទោះបីជាមានការពាក់ព័ន្ធនៅដើមដំបូងពីសេវាកម្មសកម្មភាពកំចាត់មីនសហប្រជាជាតិ (UNMAS)ក៏ដោយ តួនាទីរបស់ UNMACC ក្នុងជំនួយជនរងគ្រោះនៅតែមានកម្រិតទាក់ទងដល់ការប្រមូលទិន្នន័យចន្លោះឆ្នាំ២០០៥-២០០៩ ហើយការវាយតម្លៃរបស់ UNMACC បានចេញជាអនុសាសន៍ឱ្យបង្កើត "គោលនយោបាយជំនួយជនរងគ្រោះដ៏មានន័យមួយ"[៣៧]។ ក្នុងឆ្នាំ២០០៩ UNMACC បានបោះជំហ៊ានទៅមុខ ដោយស្វែងរកជួលអ្នកសម្របសម្រួលជំនួយជនរងគ្រោះ ដើម្បីសម្របសម្រួលការគ្រប់គ្រងទិន្នន័យពីជនរងគ្រោះ ការសម្របសម្រួល និងរៀបចំធ្វើផែនការជំនួយជនរងគ្រោះ និងការទំនាក់ទំនងជាមួយក្រសួងសុខាភិបាល សង្គមកិច្ច និងគ្រួសារ ពាក់ព័ន្ធបញ្ហាជំនួយជនរងគ្រោះ។ មកដល់ពាក់កណ្តាលខែមិថុនា ឆ្នាំ២០០៩ តួនាទីនេះ នៅមិនទាន់បានបំពេញនៅឡើយ[៣៨] ប៉ុន្តែតួនាទីនេះ អាចត្រូវបានគេមើលឃើញថា ជាការប៉ុនប៉ងដើម្បីជួយធ្វើឱ្យប្រសើឡើងដល់ការធ្វើផែនការ និងការសម្របសម្រួលអន្តរក្រសួង។ ការវាយតម្លៃរបស់ UNMACC បានផ្តល់អនុសាសន៍ឱ្យប្រតិបត្តិករសកម្មភាពកំចាត់មីនធ្វើការច្រើនជាងមុនដើម្បីជួយដល់អ្នកនៅរស់រានមានជីវិតពីគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្រ្គាម តាមរយៈកម្មវិធីដ៏សមស្របដែលមានស្រាប់ក្នុងវិស័យសុខាភិបាល វិស័យសង្គម និងសេដ្ឋកិច្ច ជាជាងបង្កើតនូវគំរាងដាច់ដោយឡែក[៣៩]។

ផែនការយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្ររបស់សាធារណរដ្ឋប្រជាមានិតកុងហ្គោ បានយោងដល់ជនពិការ និងសកម្មភាពដែលអាចធ្វើបានមួយចំនួន រួមមានការបង្កើតកម្មវិធីថ្នាក់ជាតិដើម្បីជនពិការ ការធ្វើឱ្យប្រសើឡើងដល់លក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមដោយលើកកម្ពស់វិស័យអប់រំ និងបណ្តុះបណ្តាល និងការធ្វើឱ្យប្រសើឡើងដល់ការគាំពារសុខភាព និងការចល័តទេ[៤០]។

មិនមានអ្នកផ្តល់ចម្លើយជាអ្នកនៅរស់រានមានជីវិតណាម្នាក់បានរាយការណ៍ថា មានការចូលរួមពីរដ្ឋាភិបាលច្រើនជាងមុនក្នុងជំនួយជនរងគ្រោះក្នុងឆ្នាំ២០០៩ជាងក្នុងឆ្នាំ២០០៥ ឬថាព័ត៌មានត្រូវបានផ្តល់អំពីសមិទ្ធិផលនៃជំនួយជនរងគ្រោះទេ។ មិនមានអ្នកផ្តល់ចម្លើយណាម្នាក់គិតថាតម្រូវការរបស់អ្នកនៅរស់រានមានជីវិតត្រូវបានយកមកពិចារណានៅពេលកំណត់អាទិភាពជំនួយជនរងគ្រោះទេ។ ភាគរយដ៏តិចតួចនៃអ្នកផ្តល់ចម្លើយ (៩%) យល់ស្របថាការដាក់បញ្ចូលអ្នកនៅរស់រានមានជីវិត និងអង្គការផ្នែកពិការភាពរបស់ពួកគេ និងការត្រួតពិនិត្យជំនួយជនរងគ្រោះបានកើនឡើង។ ប៉ុន្តែមិនមានការរាយការណ៍ពីភាពរីកចំរើនណាមួយពាក់ព័ន្ធនឹងការដាក់បញ្ចូលអ្នកនៅរស់រានមានជីវិត ឬអង្គការតំណាងរបស់ពួកគេ ក្នុងការអនុវត្តសេវាកម្មជំនួយជនរងគ្រោះ ឬគោលនយោបាយអភិវឌ្ឍន៍នោះទេ។

## សេចក្តីសន្និដ្ឋាន

- ដោយសារស្ថានភាពធ្ងន់ធ្ងរនៅក្នុងសាធារណរដ្ឋប្រជាមានិតកុងហ្គោ ជំនួយជនរងគ្រោះ/ពិការភាព មិនត្រូវបានគេចាត់ទុកជាអាទិភាព។
- ដោយសារការខូចខាតប្រព័ន្ធសុខាភិបាល ទើបខ្លួនត្រូវការកិច្ចខិតខំប្រឹងប្រែងច្រើនជាងវិធានការណ៍ជំនួយជនរងគ្រោះ ដែលអាចសម្រេចបាន។
- អរគុណដល់ប្រតិបត្តិករជាអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើឱ្យការឆ្លើយតបបានប្រសើឡើងជាច្រើនក្នុងវិស័យស្តារកាយសម្បទា ប៉ុន្តែ

សេវាកម្មទាំងនេះនៅមិនទាន់គ្រប់គ្រាន់នៅឡើយ ។

- ការគាំទ្រផ្នែកស្ថាប័ន អន្តរជាតិចំពោះជំនួយជនរងគ្រោះ កំពុងមានការខ្វះខាត ហើយការសម្របសម្រួលចំពោះជំនួយជនរងគ្រោះ ឬពិការភាពរវាងក្រសួងពាក់ព័ន្ធ ក៏នៅមិនទាន់បានគ្រប់គ្រាន់ផងដែរ ។
- ការខ្វះខាតជនបង្គោលដែលមានអាណត្តិច្បាស់លាស់ បានរារាំងដល់ការរៀបចំធ្វើផែនការ ដូចគ្នានឹងការមិនមានទិន្នន័យដែលត្រឹមត្រូវ ។ ទោះជាយ៉ាងណាក៏ដោយ ចំនុចទីពីរនេះ មិនបានចាត់ទុកថាជាហេតុផលសមរម្យចំពោះការខ្វះខាតការរីកចំរើនឡើយ ។
- ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដើម្បីអនុវត្ត PNRBC ត្រូវអាក់ខាន ។
- អង្គការក្នុងស្រុក និងអន្តរជាតិជាច្រើន ផ្តោតសំខាន់ទៅលើស្ថានសង្គ្រោះបន្ទាន់ និងមិនបញ្ចូលពីតម្រូវការរបស់អ្នកនៅរស់រានមានជីវិតពីគ្រាប់មីន ឬកាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម ឬជនពិការផ្សេងទៀតនៅក្នុងកម្មវិធីរបស់ពួកគេជាប្រព័ន្ធ ។

## ការស្នើរឡើងសម្រាប់ផែនការអនាគត

នៅពេលសួរអំពីក្តីរំពឹងទុករបស់ពួកគេ អ្នកផ្តល់ចម្លើយជិតពាក់កណ្តាល (៤៧%) គិតថាស្ថានភាពរបស់ពួកគេ ៥ ឆ្នាំបន្ទាប់នឹងអាក្រក់ជាងពេលបច្ចុប្បន្ន ២៤% ជឿជាក់ថា វានឹងមានភាពប្រសើជាងនេះ និង២៧%និយាយថា វានឹងនៅដដែល ។

ដើម្បីជួយឱ្យមានអនាគតល្អជាងនេះនៅពេលខាងមុខ សំណូមពរមួយចំនួន អាចយកមកពិចារណា ដូចខាងក្រោម:

- ផ្តល់ការគាំទ្រដល់ជនបង្គោលទទួលខុសត្រូវជំនួយសង្គ្រោះរបស់រដ្ឋាភិបាល ឧទាហរណ៍តាមរយៈការគាំទ្ររបស់ UNMACC ដើម្បីបង្កើតយន្តការសម្របសម្រួលទូលំទូលាយជាងមុន ជាមួយនឹងសមត្ថភាពពេញលេញដើម្បីអនុវត្ត ។
- អនុវត្តការប៉ាន់ប្រមាណពីតម្រូវការដ៏ពេញលេញ ទៅតាមស្ថានភាពជាក់ស្តែង ប៉ុន្តែមិនត្រូវឱ្យភាពរីកចំរើនរបស់ផែនការអាស្រ័យតែទៅលើការប៉ាន់ប្រមាណនេះទេ ។
- បង្កើតផែនការពិការភាព ឬសំណុំនៃផែនការសម្រាប់វិស័យសេវាកម្មនីមួយៗ ដែលបង្កើតឡើងដោយក្រសួងពាក់ព័ន្ធក្នុងកិច្ចពិគ្រោះយោបល់ ជាមួយអង្គការអន្តរជាតិ អង្គការក្នុងស្រុក និងអ្នកនៅរស់រានមានជីវិត ។
- បង្កើនការសម្របសម្រួលរវាងក្រសួង UNMACC និងអង្គការ ដើម្បីធ្វើឱ្យប្រសើឡើងដល់ការអនុវត្ត និងការរាយការណ៍ និងដើម្បីគាំទ្រការអនុវត្តរបស់ PNRBC ។
- រៀបចំសំណើរសុំថវិកាគំរោងពិការភាព/ជំនួយជនរងគ្រោះ ។

តើអ្នកគិតថាស្ថានភាពរបស់អ្នកនឹងដូច៥ឆ្នាំមុនដែររឺទេ?




- ផ្តល់សិទ្ធិអំណាចដល់សេវាកម្មតាមមូលដ្ឋាន លើកទឹកចិត្តគំរោងតាមមូលដ្ឋាន ដែលត្រូវការថវិកាអនុវត្តគំរោងក្នុងកម្រិតអប្បរមា ។
- ណែនាំនូវគំរោងសាកល្បងសម្រាប់ការបញ្ចូលផ្នែកសេដ្ឋកិច្ច ដូចជាវគ្គបណ្តុះបណ្តាល និងឥណទានខ្នាតតូច នឹកគិតពិចារណាឡើងវិញពីស្ថានភាពសេដ្ឋកិច្ចដែលធ្លាក់អន់ខ្សោយ និងការបន្សីទៅតាមលក្ខខ័ណ្ឌនៅមូលដ្ឋាន
- បង្កើតអង្គការអ្នកនៅរស់រានមានជីវិត និងក្រុមគាំទ្រអ្នកដែលមានវ័យប្រហាក់ប្រហែលគ្នាជាជម្រើសដ៏មានប្រសិទ្ធផល ចំពោះការបង្កើតយន្តការប្រឹក្សាយោបល់ពាក់ព័ន្ធចិត្តសាស្ត្រផ្លូវការ ។

**សំដីជនរងគ្រោះផ្ទាល់...**

ប្រសិនបើប្រទេសទាំងឡាយពិតជាយកចិត្តទុកដាក់ដល់អ្នកនៅរស់រានមានជីវិតមែននោះ ពួកគេគួរតែ :

- ផ្ដល់ទីជំរកដល់អ្នកនៅរស់រានមានជីវិត
- ផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ
- កសាងទីលំនៅ
- ផ្ដល់ម៉ាស៊ីនដេរ
- លើកកម្ពស់ការសម្របសម្រួលការអនុវត្តជំនួយសង្គ្រោះ
- ផ្ដល់ជំនួយដើម្បីទទួលបានឧបករណ៍ទ្រទ្រង់រាងកាយសប្បនិម្មិត
- ស្ថាបនាមណ្ឌលជំនួយសង្គ្រោះ
- ទទួលខុសត្រូវចំពោះតម្រូវការផ្នែកសេដ្ឋកិច្ច និងចិត្តសង្គមរបស់អ្នកនៅរស់រានមានជីវិត

**សំដីជនរងគ្រោះផ្ទាល់...**

អាទិភាពចំបងសម្រាប់ជំនួយសង្គ្រោះប្រាំឆ្នាំបន្ទាប់ រួមមាន:

- លើកកម្ពស់សេវាស្តារលទ្ធភាពពលកម្ម
- រក្សាសន្តិភាព
- បញ្ចូលផ្នែកសេដ្ឋកិច្ចទៅក្នុងផែនការជាតិ
- ដាក់បញ្ចូលអ្នកនៅរស់រានមានជីវិតទៅក្នុងសកម្មភាព
- បង្កើតមជ្ឈមណ្ឌលសមាហរណកម្ម
- ដាក់បញ្ចូលសកម្មភាពសមាហរណកម្មទៅក្នុងថវិកាជាតិ

**សំដីជនរងគ្រោះផ្ទាល់...**

អ្នកនៅរស់រានមានជីវិត ចាត់ទុកខ្លួនពួកគេថាជា : ក្មេងប្រុសពោះម៉ាយ សិស្ស ដែលត្រូវពឹងពាក់ឪពុកម្ដាយ ស្ត្រី អ្នកដែលមានដៃជើងល្អត្រឹមត្រូវ អ្នកជឿជាក់ ជនពិការ ឪពុក អ្នកដែលអត់មានការគាំទ្រ កូនៗ អ្នកនៅនៅលីវ អ្នកនៅរស់រានមានជីវិត និងក្មេងដែលបានរាបការ ។

**ពាក្យសំដីផ្ទាល់ខ្លួន...**

មានគំនិតផ្សេងៗគ្នាត្រូវបានសំដែងចេញនៅក្នុងចម្លើយស្ទង់មតិ និងមានចម្លើយខ្លះត្រូវបានជ្រើសរើសដើម្បីដាក់បញ្ចូលយោបល់ខ្លះៗអំពីសេវាកម្ម ដូចជា :

- "បន្ទាប់ពីជួបឧប្បត្តិហេតុ អ្វីៗនៅតែប្រព្រឹត្តទៅបានល្អ ហើយខ្ញុំត្រូវបានព្យាបាលយ៉ាងត្រឹមត្រូវ។ ប៉ុន្តែមានម្ដងនោះ ដែលថាខ្ញុំមានសុខភាពល្អ លែងជាការពិតទៀត។ នៅពេល ដែលខ្ញុំមានបញ្ហាសុខភាព អ្វីៗមានការលំបាកជាខ្លាំងនៅពេលបច្ចុប្បន្ននេះ : អត់មានលុយ អត់មានលទ្ធភាពទទួលបានសេវា។ ការបំលាស់ទីក្បែរៗខាង គឺជាបញ្ហាផងដែរ វាធ្លាប់ជាសិទ្ធិមួយ (របស់ជនពិការ) ក្នុងការជិះតាក់ស៊ីដោយឥតគិតថ្លៃ ប៉ុន្តែបញ្ហានេះលែងកើតមានទៀតហើយនៅ Kisangani ពីព្រោះអ្នកបើកបរបដិសេធមិនព្រមដឹកយើង។ យើងអត់មានអំណាច ពីព្រោះគ្មាននរណាម្នាក់និយាយរកយើង"។
- ពួកគេគួរតែយកចិត្តទុកដាក់ដល់គ្រប់ជនរងគ្រោះ។ ខ្ញុំពិការនៅថ្ងៃនេះដោយសារតែខ្ញុំច្បាំងដើម្បីប្រទេសនេះ។ រដ្ឋាភិបាល គួរតែថ្លែងអំណរគុណ និងជួយយើង មិនមែនបោះបង់យើងចោលនោះទេ។
- រដ្ឋាភិបាលគួតែធ្វើអ្វីមួយដើម្បីខ្ញុំ ពីព្រោះខ្ញុំខិតជិតទៅរកសេចក្ដីស្លាប់ ... គេគួរតែយកចិត្តទុកដាក់ចំពោះរូបខ្ញុំ និងទិញផ្ទះមួយសម្រាប់ខ្ញុំ ហើយក្រោយមកខ្ញុំអាចស្លាប់ដោយសុខស្រួលបាននៅក្នុងផ្ទះនោះ"។

**សំដីជនរងគ្រោះផ្ទាល់..........**

**បទពិសោធន៍ជីវិតរបស់**

Théthé Solo Lembenda

អំឡុងសង្គ្រាមរយះពេលប្រាំមួយថ្ងៃ រវាងកងកំលាំងប្រដាប់អាវុធ Rwandan និង Ugandan ក្នុងឆ្នាំ២០០១ នៅគីសានកានី កញ្ញាថេថេ ទើបតែមានអាយុ៦ឆ្នាំ ដែលនៅពេលនោះនាងបាន ជាន់មីន។ នាងត្រូវបានយកទៅសំរាក ព្យាបាលដោយ ICRC នៅមន្ទីរពេទ្យធំ Kisangani ចំណែកឧបករណ៍ទ្រទ្រង់រាង កាយនាងដំបូងគេបង្អស់ត្រូវបានគាំទ្រពីអង្គការអន្តរជាតិមួយ។ តាមរយៈអង្គការនេះ នាងបានទទួលការគាំទ្រផ្នែកចិត្តសង្គមផងដែរ ដើម្បីជួយឱ្យនាងអាចទទួលយកស្ថាន ភាពិការរបស់នាងបាន។

ជាលទ្ធផល នាងមិនត្រូវបានទាត់ចេញពីគ្រួសាររបស់នាង ឬពីសហគមន៍របស់នាងឡើយ ហើយឥឡូវនេះ នាងកំពុងសិក្សាពាណិជ្ជកម្មនៅវិទ្យាល័យ។ បន្ទាប់ពីការសិក្សានៅវិទ្យាល័យ នាងចង់ ទទួលបានការគាំទ្រ ដើម្បីឱ្យនាងអាចទៅរៀនបន្តនៅសាកលវិទ្យាល័យ និងក្រោយមកអាចចាប់ ផ្ដើមគំរោងបញ្ចូលផ្នែកសេដ្ឋកិច្ច ដើម្បីជួយដល់ជនពិការដទៃទៀត។

# DR Congo

[1] See *Landmine Monitor Report 2008*, Ottawa, October 2008, p. 281; and ICBL, *Landmine Monitor Report 1999*, Washington, DC, May 1999, p.192.

[2] See *Landmine Monitor Report 2008*, Ottawa, October 2008, p. 281.

[3] UNDP, "2008 Statistical Update − Congo (Democratic Republic of the)," http://hdrstats.undp.org/en/countries/data_sheets/cty_ds_COD.html, accessed 22 July 2009; and UNDP, *Human Development Report 2004: Cultural Liberty in Today's Diverse World*, New York, 2004, p. 142.

[4] World Bank, "Gross national income per capita 2008, Atlas method and PPP," 1 July 2009, http://siteresources.worldbank.org/DATASTATISTICS/Resources/GNIPC.pdf; and UN Statistics Division, "Per capita GNI at current prices – US Dollars," http://data.un.org/Data.aspx?d=SNAAMA&f=grID%3A103%3BcurrID%3AUSD%3BpcFlag%3A1, accessed 22 July 2009.

[5] CIA, *The World Factbook – Congo, Democratic Republic of the*, 2008, https://www.cia.gov/library/publications/the-world-factbook/geos/cg.html, and 2004, http://www.umsl.edu/services/govdocs/wofact2004/geos/cg.html; and Jason K. Stearns, "Congo's Peace: Miracle or Mirage,"*Current History*, 23 April 2007, http://www.crisisgroup.org/home/index.cfm?id=4799&l=1, accessed 22 July 2009.

[6] WHO, "Detailed Database Search: Democratic Republic of Congo," http://apps.who.int/whosis/data/Search.jsp?indicators=%5bIndicator%5d.%5bHSR%5d.Members, accessed 22 July 2009.

[7] WHO, "World Health Statistics 2009," Geneva, 2009, pp. 95-96. The WHO estimates that countries with less than 23 healthcare professionals (physicians, nurses and midwives) per 10,000 population are unlikely to achieve adequate coverage.

[8] UN, Convention [on the Rights of Persons with Disabilities] & Optional Protocol Signatories & Ratification," http://www.un.org/disabilities/countries.asp?id=166, as accessed on 1 August 2009, delays in updating the webpage were noted.

[9] UN, "2009 Portfolio of Mine Action Projects," New York, December 2008, p. 151.

[10] OXFAM, "Conflict in the Democratic Republic of the Congo – In depth," 2009, http://www.oxfam.org/emergencies/congo/in-depth; CARE, "Situation Worsens in Democratic Republic of Congo," http://www.care.org/newsroom/articles/2007/10/20071016_drc_main.asp, and CIA, *The World Factbook – Congo, Democratic Republic of the*, 2008, https://www.cia.gov/library/publications/the-world-factbook/geos/cg.html, accessed 22 July 2009

[11] DRC, Article 7 Report (for calendar year 2008), Form J, 27 May 2009.

[12] Médecins sans Frontières (MSF), "MSF in Democratic Republic of Congo," Last updated: April 2009, http://doctorswithoutborders.org/news/country.cfm?id=2290, accessed 22 July 2009; and UNICEF, "UNICEF situation report North and South Kivu, Ituri, Haut-Uélé, DR Congo 06-20 May 2009," 20 May 2009.

[13] "Final Report of the Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, p.145.

[14] See the DRC chapter in *Landmine Monitor Reports*, 1999-2008; and "Final Report of the Meeting of States Parties / Zagreb Progress Report,"Part II, Annex V, Zagreb, 28 November-2 December 2005, pp. 141-145.

[15] Questionnaire responses were provided through the mine risk education network supported by HI and by the ICRC.

[16] "Final Report of the Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, pp. 140-141.

[17] "DRC: Ailing health system needs a cure," *IRIN* (Kinshasa), 30 June 2006.

[18] ICBL, *Landmine Monitor Report 2007*, Ottawa, October 2007, p. 302.

[19] Statement of the DRC, Ninth Meeting of States Parties, Geneva, 27 November 2008; USAID, "Democratic Republic of the Congo: Complex Emergency Situation Report #2 (FY 2009)," 4 June 2009, www.usaid.gov/our_work/humanitarian_assistance/disaster_assistance/countries/drc/template/fs_sr/fy2009/drc_ce_sr02_06-4-2009.pdf, ; MSF, "MSF in Democratic Republic of Congo," April 2009, http://doctorswithoutborders.org/news/country.cfm?id=2290; UNICEF, "UNICEF situation report North and South Kivu, Ituri, Haut-Uélé, DR Congo 06-20 May 2009," 20 May 2009; and ICRC, "Democratic Republic of the Congo: concern over humanitarian situation in the Kivus," 27 January 2009, www.icrc.org/web/eng/siteeng0.nsf/htmlall/congo-kinshasa-update-270109?opendocument, accessed 22 July 2009.

[20] ICRC, Physical Rehabilitation Programme: Annual Reports 2005-2008, Geneva, June 2006-May 2009.

[21] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 289.

[22] "Final Report of the Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, pp.143-144.

[23] ICBL, *Landmine Monitor Report 2007*, Ottawa, October 2007, p. 302; and *Landmine Monitor Report 2008,* Ottawa, October 2008, p. 289.

[24] Statement of the DRC, Eighth Meeting of States Parties, Dead Sea, 21 November 2007.

[25] MSF, "Condition Critical: Voices from the war in eastern Congo," 20 November 2008, www.condition-critical.org/condition-critical-voicesfrom-the-war-in-eastern-congo, and UNICEF, "As DR Congo crisis persists, UN classifies rape as weapon of war," 24 June 2008, www.unicef.org/infobycountry/drcongo_44598.html, accessed 22 July 2009.

[26] Statement of the DRC, Ninth Meeting of States Parties, Geneva, 27 November 2008.

[27] "Final Report of the Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, pp. 144-145; US Department of State, "2008 Country Reports on Human Rights Practices: Democratic Republic of Congo," Washington, DC, 25 February 2009; and ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 289.

[28] Email from Violaine Fourile, Coordinator, Mine Action Program, HI, 23 April 2009.

[29] See *Landmine Monitor Report 2008,* Ottawa, October 2008, p. 290; Statement by the DRC, Ninth Meeting of States Parties, Geneva, 27 November 2008; Article 7 report, (for calendar year 2008), Form J. 2009.

[30] Email from Violaine Fourile, Coordinator, Mine Action Program, HI, 23 April 2009.

[31] US Department of State, "2008 Country Reports on Human Rights Practices: Democratic Republic of Congo," 25 February 2009; and *Landmine Monitor Report 2008,* Ottawa, October 2008, pp. 289-290.

[32] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 289.

[33] Anne Capelle and Chris Lang, "Mission d'évaluation du programme de lutte antimines de l'Organisation des Nations Unies en République Démocratique du Congo Mars-Avril 2008" ("Evaluation of the United Nations mine action programme in DRC, March-April 2008"), for UNMAS (undated), p. 33.

[34] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 290; and DRC, Article 7 Report (for calendar year 2008), Form J, 27 May 2009.

[35] DRC, Article 7 Report (for calendar year 2008), Form J, 27 May 2009.

[36] ICBL, *Landmine Monitor Report 2005*, Ottawa, October 2005, p. 296.

[37] Anne Capelle and Chris Lang, "Mission d'évaluation du programme de lutte antimines de l'Organisation des Nations Unies en République Démocratique du Congo Mars-Avril 2008" ("Evaluation of the United Nations mine action programme in DRC, March-April 2008"), for UNMAS (undated), p. 9.

[38] Email from Salim Raad, Deputy Program Manager, UNMACC, 17 June 2009.

[39] Anne Capelle and Chris Lang, "Mission d'évaluation du programme de lutte antimines de l'Organisation des Nations Unies en République Démocratique du Congo Mars-Avril 2008" ("Evaluation of the United Nations mine action programme in DRC, March-April 2008"), for UNMAS (undated), p. 33.

[40] International Monetary Fund (IMF), "Democratic Republic of the Congo: Poverty Reduction Strategy Paper," (IMF Country Report No.07/330), September 2007, p. 87.